**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ.១៥៧..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋានផ្លូវដែក ចំណុះក្រសួងសាធារណការ និងដឹកជញ្ជូន

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

## សម្រេច

**មាត្រា ១ :** ត្រូវបានបង្កើតនាយកដ្ឋានផ្លូវដែក ចំណុះក្រសួងសាធារណការ និងដឹកជញ្ជូន។

**មាត្រា ២ :** នាយកដ្ឋានផ្លូវដែក មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- សិក្សា ស្រាវជ្រាវ និងតាក់តែងគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងការអភិវឌ្ឍន៍ និងទំនើបកម្មប្រព័ន្ធបណ្តាញគមនាគមន៍ផ្លូវដែកនៅកម្ពុជា តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីបំពីអោយការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចរបស់កម្ពុជា ប្រកបដោយប្រសិទ្ធភាព និងមានភាពប្រកួតប្រជែងខ្ពស់។
- សិក្សា ស្រាវជ្រាវ និងតាក់តែងចងក្រងក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋាននានា ពាក់ព័ន្ធនឹងផ្លូវដែក។

- សិក្សា ស្រាវជ្រាវ និងតាក់តែងចងក្រងបទដ្ឋានបច្ចេកទេស សំរាប់បំរើអោយការគ្រប់គ្រង ការថែទាំ ការជួសជុល និងការអភិវឌ្ឍន៍នូវរាល់បណ្តាហេដ្ឋារចនាសម្ព័ន្ធទាំងអស់ពាក់ព័ន្ធនឹងផ្លូវដែក។

- សិក្សា និងរៀបចំតាក់តែងចងក្រងបទដ្ឋាន និងគោលការណ៍ណែនាំនានា សំរាប់បំរើអោយ ការងារត្រួតពិនិត្យ ការរក្សាសណ្តាប់ធ្នាប់ សន្តិសុខ ចរាចរខ្សែរថភ្លើង និងប្រតិបត្តិការផ្លូវដែក ព្រមទាំងបទដ្ឋានពាក់ព័ន្ធនឹងសុវត្ថិភាព ក្នុងការដឹកជញ្ជូនតាមផ្លូវដែក ទាំងការដឹកជញ្ជូនអ្នកដំណើរ និង ទំនិញគ្រប់ប្រភេទ។

- បំពេញភារកិច្ចផ្សេងទៀត តាមការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

**មាត្រា ៣ :** នាយកដ្ឋានផ្លូវដែក ត្រូវបានដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការ ចាំបាច់។

**មាត្រា ៤ :** ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានផ្លូវដែក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង សាធារណការ និងដឹកជញ្ជូន។

**មាត្រា ៥ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៦:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង សាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការដ្ឋានគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ០៧ ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ត្រាំ អ៊ីវតឹក**

***កន្លែងទទួល:***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*